**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១៦ . សសរ

# សេចក្ដីសម្រេច

# ស្ដីពី

# ការកែសម្រួលសមាសភាពគណៈកម្មការចម្រុះ បង្ក្រាបការលេង ល្បែងកាស៊ីណូ ឆ្នោត-ឡូតូ ភ្នាល់ផ្ទាល់ ភ្នាល់អនឡាញ និងល្បែងភ្នាល់ខុសច្បាប់គ្រប់ប្រភេទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៨ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្ក្រាបល្បែងស៊ីសង
- បានឃើញអនុក្រឹត្យលេខ១៦អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ០៤អនក្រ.បកចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញសេចក្តីសម្រេចលេខ៣៥សសរ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មការចម្រុះដើម្បីបង្ក្រាបល្បែងឆ្នោត-ឡូតូ ភ្នាល់បាល់ ល្បែងកំសាន្តស្លុតម៉ាស៊ីន និងបនល្បែងស៊ីសងខុសច្បាប់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១** ត្រូវបានកែសម្រួលសមាសភាពគណៈកម្មការចម្រុះបង្ក្រាបការលេងល្បែងកាស៊ីណូ ឆ្នោត-ឡូតូ ភ្នាល់បាល់ ភ្នាល់អនឡាញ និងល្បែងភ្នាល់ខុសច្បាប់គ្រប់ប្រភេទ ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោកជំទាវ **ខូន សុខា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាប្រធាន |
| ២. ឯកឧត្តមនាយឧត្តមសេនីយ៍ **ឯម សំអាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣. ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ៤. ឯកឧត្តម **សូ ឧុចធ័រ** | ទីប្រឹក្សាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៥. ឯកឧត្តម **ម៉ី ម៉ាន់** | អគ្គនាយកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦. ឯកឧត្តមឧត្តមសេនីយ៍ឯក **ឆៃ ស៊ីណារិទ្ធ** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៧. លោក **រស់ តរុណា** | អគ្គនាយករងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក និងជាលេខាអចិន្ត្រៃយ៍ |
| ៨. ឯកឧត្តមឧត្តមសេនីយ៍ទោ **សៀង សេន** | ប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុង (កមផ) | សមាជិក និងជាលេខាអចិន្ត្រៃយ៍ |

**ប្រការ ២** គណៈកម្មការចម្រុះបង្ក្រាបការលេងល្បែងកាស៊ីណូ ឆ្នោត-ឡូតូ ភ្នាល់បាល់ ភ្នាល់អនឡាញ និងល្បែងភ្នាល់ខុសច្បាប់គ្រប់ប្រភេទ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

១. សហការក្នុងការការពារសិទ្ធិធ្វើអាជីវកម្មស្របច្បាប់របស់ក្រុមហ៊ុនទាំងឡាយ កំពុងប្រកបអាជីវកម្មកាស៊ីណូ ឆ្នោត-ឡូតូ និងល្បែងភ្នាល់គ្រប់ប្រភេទ ដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាល និងអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២. ចាត់វិធានការបង្ក្រាប និងលុបបំបាត់ការធ្វើអាជីកម្មកាស៊ីណូ ឆ្នោត-ឡូតូ ភ្នាល់បាល់ ភ្នាល់អនឡាញ និងល្បែងភ្នាល់គ្រប់ប្រភេទ ព្រមទាំងអាជីវកម្មរណបផ្សេងៗ ដំណើរការអាជីវកម្មដោយគ្មានការអនុញ្ញាតពីរាជរដ្ឋាភិបាល និងអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣. ចាត់វិធានការបង្ក្រាបអាជីវកម្មទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទានខុសច្បាប់ទាំងអស់ ដែលកំពុងធ្វើអាជីវកម្មដែលគ្មានអាជ្ញាបណ្ណពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៣** គណៈកម្មការចម្រុះបង្ក្រាបការលេងល្បែងកាស៊ីណូ ឆ្នោត-ឡូតូ ភ្នាល់បាល់ ភ្នាល់អនឡាញ និងល្បែងភ្នាល់ខុសច្បាប់គ្រប់ប្រភេទ មានសិទ្ធិបង្កើតអនុគណៈកម្មការសម្រាប់ធ្វើប្រតិបត្តិការបង្ក្រាប

ការលេងល្បែងកាស៊ីណូ ឆ្នោត-ឡូតូ ភ្នាល់បាល់ ភ្នាល់អនឡាញ និង ល្បែងភ្នាល់ខុសច្បាប់គ្រប់ប្រភេទ និងការធ្វើអាជីវកម្មទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទានខុសច្បាប់ទាំងអស់នៅតាមរាជធានី-ខេត្តទូទាំងប្រទេស។

**ប្រការ ៤** សេចក្តីសម្រេច និងលិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងប្រការមួយ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ